# ការស្តារសេចក្តីជំនឿនៅក្នុងក្រុមគ្រួសារ

អែលឌើរ ខែនីស ចនសុន
នៃពួក 70 នាក់

*គ្រួសារដែលមានស្នេហភាពផ្តល់ជាក្រណាត់ដែលរុំខ្ចប់សង្គមជាមួយគ្នា ដែលផ្តល់អត្ថប្រយោជន៍ទៅដល់មនុស្សលោក ទាំងអស់គ្នា ។*

ជាមួយនឹងចំណេះដឹងនៃ "ផែនការនៃសុភមង្គលដ៏មហិមា"1 យើងមានឱកាស និងការទទួលខុសត្រូវផងដែរ ដើម្បីជួយស្តារសេចក្តីជំនឿនៅក្នុងក្រុមគ្រួសារ ។

តាមមធ្យោបាយជាច្រើន ការទទួលខុសត្រូវរបស់យើង គឺអាចប្រៀបធៀបបាននឹងជនទាំងឡាយណា ដែលធ្វើការនៅក្នុងផ្នែកស្រាវជ្រាវខាងវិជ្ជាពេទ្យ និងវិទ្យាសាស្ត្រ ។ ការប្រើប្រាស់ច្បាប់ទាំងឡាយដែលបានស្ថាបនាឡើង ពួកគេបានកំណត់ពីរបៀបដែលការទទួលរងការឈឺចាប់អាចធ្វើឱ្យមានការធូរស្រាល និងអភិវឌ្ឍគុណភាពនៃជីវិត ។

នៅក្នុងអាណាចក្រនៃជំនឿសាសនា បុរស និងស្ត្រីនៃជំនឿទាំងឡាយ ដោយបានប្រើប្រាស់គោលការណ៍ដែលបានស្រាយបំភ្លឺ2 អាចជួយព្យាបាលដួងចិត្តដែលឈឺចាប់ ស្តារសេចក្តីសង្ឃឹមឡើងវិញ និងការអះអាងដល់គំនិតដែលស្ទុតស្ទាញ ។

ជោគជ័យរបស់អ្នកវិទ្យាសាស្ត្របានត្រូវសំរេចឡើងដោយអនុវត្តតាមអ្វីដែលជាញឹកញាប់ត្រូវបានស្គាល់ថា ជាច្បាប់នៃធម្មជាតិ ។ ពួកអ្នកវិទ្យាសាស្ត្រដ៏ឆ្នើមទាំងឡាយទាំងនៅពេលអតីតកាល និងបច្ចុប្បន្នកាល មិនបានបង្កើតច្បាប់ទាំងឡាយដែលទាក់ទងនឹងដំណើរការកើតឡើងតាមធម្មជាតិទាំងនេះទេ : ពួកគេបានស្រាវជ្រាវឃើញដំណើរការនេះ ។

នៅក្នុងសារលិខិតទៅកាន់ កូរិនថូស សាវកប៉ុល បានចោទសួរនូវសំណួរដ៏គួឱ្យចាប់អារម្មណ៍មួយ ដែលទាក់ទងនឹងធនធាននៃសមត្ថភាពខាងប្រាជ្ញារបស់មនុស្សថាៈ "ត្បិតបើមិនមែនជាវិញ្ញាណនៅក្នុងខ្លួនមនុស្សទេ នោះតើមានអ្វីនឹងស្គាល់សណ្តានមនុស្សនោះបាន?"3

តាមរយៈកត្តិវិជ្ជា និងការរៀនសូត្រ ចំណេះដឹងត្រូវបានបង្កើនឡើង ហើយការយល់ដឹងត្រូវបានដាក់បន្ថែម ។ ការប្រើប្រាស់ ដំណើរការនេះ ទ្រឹស្តី និងច្បាប់ទាំងឡាយ គឺត្រូវបានគូសបញ្ជាក់ ហើយបានទទួលយកដោយត្រឹមត្រូវតាមច្បាប់ ។

កិច្ចការមួយដែលបញ្ជាក់យ៉ាងច្បាស់លាស់ចំពោះគំនិតដែលបានស្រាយបំភ្លឺ គឺថាមានច្បាប់ដែលរក្សាជីវិត និងវត្ថុដែលមានជីវិតឱ្យមានតុល្យភាព ។ ការរកឃើញនូវច្បាប់នៃរូបសាស្ត្រ ហើយអនុវត្តតាមការរកឃើញទាំងនោះ បាននាំមកនូវការរីកចំរើនដែលអាចធ្វើឱ្យមនុស្សរីកចំរើនដល់កំរិតដែលទទួលបានកាន់តែប្រសើរឡើងតាមដែលអាចធ្វើទៅបាន ។

ខ្ញុំជឿថា ការសន្មត់នេះក៏អាចអនុវត្តចំពោះបទដ្ឋាននៃសីលធម៌ និងតម្លៃសីលធម៌ផងដែរ ។ ហេតុដូច្នេះហើយវាជាការទទួលខុសត្រូវរបស់យើង ដើម្បីការពារគេហដ្ឋានដែលជាចំនុចសំខាន់នៃការរៀនសូត្រ ជាកន្លែងដែលគុណធម៌ទាំងនេះអាចត្រូវបានបំពាក់បំប៉ននៅក្នុងបរិយាកាសនៃសេចក្តីស្រឡាញ់ និងតាមរយៈអានុភាពនៃគំរូ ។4

ប្រធានថូម៉ាស អេស ម៉នសុន បានបង្រៀនថាៈ "យុវវ័យត្រូវការការរិះគន់កាន់តែតិច ហើយភាពថ្លៃថ្នូរកាន់តែច្រើន" ។5

ដោយសញ្ជឹងគិតអំពីជីវិតរបស់ខ្ញុំផ្ទាល់ ខ្ញុំដឹងពីរបៀបដែលខ្ញុំបានកើនទនូវអំណរគុណចំពោះតម្លៃដែលមានខ្លឹមសារដែលជាការចាំបាច់សំរាប់ការអភិវឌ្ឍបុគ្គលិកលក្ខណៈល្អ ។ តើខ្ញុំបានរៀនស្ដីពីភក្ដីភាព ភាពថ្លៃថ្នូរ និងភាពអាចទុកចិត្តបាននៅឯណា? ខ្ញុំបានរៀនគុណសម្បត្តិទាំងនេះនៅក្នុងគេហដ្ឋាន ចេញមកពីគំរូនៃឪពុកម្ដាយរបស់ខ្ញុំ ។ តើខ្ញុំបានទទួលនូវអំណរគុណចំពោះតម្លៃនៃការបំរើដោយមិនគិតពីខ្លួនឯងយ៉ាងដូចម្ដេច? ខ្ញុំបានធ្វើដូច្នេះដោយគោរពតាម និងរីករាយជាមួយនឹងការពលិកម្មរបស់ម្ដាយខ្ញុំចំពោះក្រុមគ្រួសាររបស់គាត់ ។ តើខ្ញុំបានរៀនអំពីការផ្ដល់កិត្តិយស និងគោរពចំពោះបុត្រីនៃព្រះនៅឯណា? ខ្ញុំបានរៀនចេញពីគំរូនៃឪពុករបស់ខ្ញុំ ។

ខ្ញុំបានរៀនក្នុងផ្ទះនូវគោលការណ៍ នៃការចេះសន្សំសំចៃក្នុងការរស់នៅ និងសេចក្ដីថ្លៃថ្នូរនៃការងារ ។ ខ្ញុំនៅតែអាចស្រមៃឃើញម្ដាយរបស់ខ្ញុំចំណាយពេលជាច្រើនយប់នៅឯផ្ទះ ដោយប្រើម៉ាស៊ីនដេរដែលប្រើដោយជើង ដើម្បីដេរស្បែកជើងសំរាប់រោងចក្រក្នុងមូលដ្ឋានមួយ ។ ការណ៍នេះគឺមិនមែនដើម្បីធ្វើសំរាប់គាត់ទិញអ្វីសំរាប់ខ្លួនឯងនោះទេ ប៉ុន្តែដើម្បីជួយផ្ដល់ការទំនុកបំរុងខាងហិរញ្ញវត្ថុ ដើម្បីឱ្យបងប្រុសរបស់ខ្ញុំ និងខ្ញុំអាចចូលរៀននៅមហាវិទ្យាល័យ ។ ក្រោយមកគាត់បានបង្ហាញថាសកម្មភាពនៃការបំរើនេះ គឺជាប្រភពដែលធ្វើឱ្យគាត់សប្បាយចិត្តយ៉ាងណា ។

ឪពុករបស់ខ្ញុំជាមនុស្សឆ្លាត ហើយឧស្សាហ៍ ។ គាត់បានបង្រៀនខ្ញុំនូវរបៀបកាប់ដើមឈើដោយប្រើរណាដៃរបៀបជួលជុល និងតំឡើងខ្សែភ្លើងដើម្បីប្រើប្រាស់នៅក្នុងផ្ទះ ព្រមទាំងជំនាញដែលមានអត្ថប្រយោជន៍ជាច្រើនទៀត ។

រាល់មេរៀនទាំងនេះមាននៅក្នុងបាវចនាជាទូទៅមួយថា: ចូរធ្វើអ្វីៗទាំងអស់ដោយអស់ពីកម្លាំងរបស់អ្នក ។

ខ្ញុំបានអភិវឌ្ឍសមត្ថភាព ដើម្បីធ្វើការសំរេចចិត្តដែលសំខាន់ៗ ដោយនិយាយជាមួយនឹងឪពុកម្ដាយរបស់ខ្ញុំ ហើយរៀនសូត្រពីពាក្យទូន្មានរបស់ពួកគាត់ ។ បន្ថែមទៅលើអ្វីដែលបានលើកឡើង: ការទទួលខុសត្រូវ ការគិតគូរចំពោះអ្នកដទៃការលើកទឹកចិត្តដើម្បីចាប់យកនូវឱកាសនៃការអប់រំ និងបញ្ជីដែលខ្ញុំបានរៀននោះនៅតែមិនទាន់បានសរសេរអស់នៅឡើយ ។

ខ្ញុំបានត្រូវណែនាំឱ្យស្គាល់ដំណឹងល្អដែលបានស្ដារឡើងវិញនៃព្រះយេស៊ូវគ្រីស្ទ ដោយ ផាម៉ែលឡា ដែលក្រោយមកនាងបានក្លាយជាភរិយារបស់ខ្ញុំ ។ នាងបានជួយឱ្យជីវិតខ្ញុំបានប្រសើរឡើងយ៉ាងខ្លាំង ។6

ខ្ញុំបានរីករាយនឹងសុភមង្គលរយៈពេល 67 ឆ្នាំនៅក្នុងអាពាហ៍ពិពាហ៍ និងជីវិតក្រុមគ្រួសារ ដោយមាន---21 ឆ្នាំធ្វើជាកូនប្រុសនៅក្នុងផ្ទះនៃឪពុកម្ដាយរបស់ខ្ញុំ និង 46 ឆ្នាំ ធ្វើជាស្វាមី ដោយបញ្ចប់នៅក្នុងសេចក្ដីអំណរដ៏ខ្លាំងបំផុតក្នុងការធ្វើជាឪពុក និងជាជីតា ។ តើមានអ្វីទៀតដែលមនុស្សម្នាក់អាចសង្ឃឹមច្រើនជាងនេះ? បើយើងនិយាយឱ្យសាមញ្ញគឺថា ឱកាសដូចគ្នានេះនឹងកើតមានដល់មនុស្សគ្រប់គ្នា ។

សូមត្រឡប់ទៅការបង្រៀនរបស់ប៉ុល ដែលបានកត់ត្រានៅក្នុងកូរិនថូសវិញ យើងបានស្វែងរកឃើញពាក្យទាំងនេះថា: "នោះតើមានអ្វីនឹងស្គាល់សណ្ឋានមនុស្សនោះបាន [លើកលែងមនុស្សនោះមាន] ព្រះវិញ្ញាណនៃព្រះ... ។ ប៉ុន្តែមនុស្សខាងសាច់ឈាម គេមិនទទួលសេចក្ដី... នៃព្រះទេ ពីព្រោះជាសេចក្ដីល្ងង់ល្ងើដល់គេ ក៏រកស្គាល់មិនបានដែរ ត្បិតត្រង់ឯសេចក្ដីទាំងនោះ ត្រូវពិចារណាយល់ខាងវិញ្ញាណវិញ" ។7

ពួកអ្នកវិទ្យាសាស្ត្របង្កើនចំណេះដឹងរបស់ពួកគេជាចម្បងតាមរយៈការស្រាវជ្រាវ ការធ្វើការពិសោធន៍ និងការអនុវត្តនូវបញ្ហា ។

ពួកសិស្សរបស់ព្រះគ្រីស្ទបានទទួលសាក្សីរបស់ពួកគេ ដោយការសិក្សាព្រះបន្ទូលរបស់ទ្រង់ សង្កេតមើលកិច្ចការរបស់ទ្រង់ ដោយការដាក់គោលការណ៍នៃដំណឹងល្អទាំងឡាយទៅជាការអនុវត្ត និងតាមរយៈវិញ្ញាណនៃការបំផុសគំនិត ។8

"មនុស្សលោកសុទ្ធតែមានវិញ្ញាណសណ្ឋិតនៅ ហើយខ្យល់ដង្ហើមនៃព្រះដ៏មានគ្រប់ព្រះចេស្ដាក៏ឱ្យមានយោបល់" ។19

ទោះជា សេចក្តីពិតខាងវិញ្ញាណអាចលេចឡើងជារឿងដែលមិនគួរឱ្យជឿចំពោះដួងចិត្តដែលរាបទាបក្តី ប៉ុន្តែឥទ្ធិពលរបស់វាមិនអាចបដិសេធបានឡើយ ។ វាជាការណ៍សំខាន់ខ្លាំងណាស់ដើម្បីយល់ថា ច្បាប់ធម្មជាតិមិនត្រូវបានកំណត់អំពីមូលដ្ឋាននៃប្រជាប្រិយភាពឡើយ ។ ច្បាប់ទាំងនេះត្រូវបានបង្កើតឡើង ហើយសង់នៅលើមូលដ្ឋាននៃសេចក្តីពិត ។

ក៏មាននូវសេចក្តីពិតខាងសីលធម៌ផងដែរ ដែលមិនបានចាប់ផ្តើមឡើងជាមួយនឹងមនុស្សទេ ។10 សីលធម៌ទាំងនេះសំខាន់ចំពោះផែនការដ៏ទេវភាព ដែលនៅពេលត្រូវបានស្រាវជ្រាវឃើញ ហើយអនុវត្តតាមនឹងនាំមកនូវសុភមង្គល និងសេចក្តី សង្ឃឹមដ៏មហិមានៅលើការធ្វើដំណើរនៃជីវិតរមែងស្លាប់នេះ ។11

ឧទាហរណ៍ ខ្ញុំជឿដូចដែលបានចែងនៅក្នុង "ក្រុមគ្រួសារៈ ការប្រកាសដល់ពិភពលោក"12 ហើយបានឱ្យនិយមន័យនៅក្នុងវិវរណៈដ៏ទេវភាព ថាអាពាហ៍ពិពាហ៍ និងក្រុមគ្រួសារគឺត្រូវបានតែងតាំងឡើងដោយព្រះ ។ ព្រះគម្ពីរបានប្រកាសថា ៖ "ដោយហេតុនោះ បានជាមនុស្សប្រុសនឹងលាចេញពីឪពុកម្តាយខ្លួន ទៅនៅជាប់នឹងប្រពន្ធវិញ ហើយអ្នកទាំងពីរនោះ នឹងត្រឡប់ជាសាច់តែមួយសុទ្ធ" ។13

ពួកអ្នកប្រាជ្ញផ្តល់ឱ្យនូវកេរដំណែល នៃការរៀនពីអតីតកាល ។ យើងត្រូវតែបន្សល់ទុកដល់ជំនាន់នាពេលអនាគតនូវគ្រឹះនៃសេចក្តីជំនឿនៅក្នុងក្រុមគ្រួសារ ដូចដែលបានកំណត់ដោយព្រះអាទិទេព ។14

យើងមិនគួរភ្លេចថា សេរីភាព និងសុភមង្គលនៅគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិតកើតឡើងតាមរយៈការយល់ដឹង និងការរស់នៅដោយសុខដុមជាមួយនឹងគោលការណ៍នៃដំណឹងល្អដ៏នៅអស់កល្បជានិច្ច ។ ពួកគេបានផ្តល់ឱ្យនូវគ្រឹះពិតប្រាកដ ដើម្បីស្ថាបនាជីវិតមួយដែលប្រកបទៅដោយភាពរុងរឿង និងភាពរីករាយ ។15

ការធ្វើតាមគំរូដែលបានពិពណ៌នាតាមរយៈផែនការនៃព្រះវរបិតា បានធ្វើឱ្យខ្ញុំបានទទួលពិសោធនូវអ្វីដែលមានន័យថា ការរស់នៅ " តាមរបៀបនៃសុភមង្គល" ។16 និងការ "ដកទឹកពីអណ្តូងនៃសេចក្តីសង្គ្រោះ... ដោយរីករាយ" ។17

ព្រះអង្គសង្គ្រោះបានបង្រៀនថាៈ "ខ្ញុំបានមកដើម្បីឱ្យវារាល់គ្នាមានជីវិត ហើយឱ្យមានជីវិតនោះពេញបរិបូរណ៍ផង" ។18

លក្ខណៈខាងក្រៅ ឬបុគ្គលិកលក្ខណៈរបស់យើង នៅពេលខ្លះអាចកំណត់សមត្ថភាពរបស់យើង ដើម្បីរីករាយនូវឱកាសដ៏មហិមានៃជីវិត ។

សំណួរអាចត្រូវបានលើកឡើងថាៈ "ចុះចំណែកជនទាំងឡាយណាដែលមិនបានជួបប្រទះនូវបរិយាកាស ក្រុមគ្រួសារដែលវិជ្ជមានវិញ?"

ក្រុមគ្រួសារដែលមានស្នេហភាព ផ្តល់ឱ្យនូវសម្ភារៈដែលលើកស្ទួយសង្គមជាមួយគ្នា ដើម្បីផ្តល់ប្រយោជន៍ដល់មនុស្សទាំងអស់ ទោះបីជាជនទាំងអស់ណាដែលអាចមានអារម្មណ៍ថា ពួកគេរស់នៅក្នុងកាលៈទេសៈដែលមិនអនុគ្រោះក្តី ។

ចំពោះជនទាំងអស់ណាដែលរស់នៅដោយស្មោះត្រង់19 ហើយអធិស្ឋានដោយអត់ធ្មត់សំរាប់សង្គមបែបនោះ20 ខ្ញុំសូមចែកចាយនូវពាក្យលួងលោមរបស់ហេលែន ស្ទីនើរ រ៉ាយថាៈ

*"នៅពេលព្រះធ្វើសេចក្តីសន្យា វានៅតែមានជារៀងរហូត*

*ត្បិតអ្វីៗដែលព្រះបានសន្យា ទ្រង់នឹងធ្វើដោយឥតក្លែងបន្លំឡើយ ។*

*នៅពេលអ្នកស្រេងាកចិត្ត ហើយរាល់សេចក្តីសង្ឃឹមត្រូវបានបំផ្លិចបំផ្លាញ*

*សូមទឹកចាំពីសេចក្ដីសន្សារបស់ព្រះ ហើយសេចក្ដីជំនឿរបស់អ្នកនឹងមានពន្លឺឡើងវិញ"*។21

នេះគឺជាការអធិស្ឋានរបស់ខ្ញុំថា យើងអាចឈរជាមួយគ្នាដោយសេចក្ដីក្លាហាន និងការជឿជាក់ ក្នុងនាមជាអណាព្យាបាលនៃក្រុមគ្រួសារជាអំណោយទានដែលព្រះបានប្រទានឱ្យ។ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។

កំណត់ចំណាំ

1. អាលម៉ា 42:8 សូមមើលផងដែរ អាលម៉ា 24:14

2. សូមមើលការណែនាំដល់បទគម្ពីរទាំងឡាយ "គោលការណ៍" 200។

3. កូរិនថូសទី 1 2:11។

4. សូមមើលសុភាសិត 22:6 ។

5. "Anxiously Engaged" លីអាហូណា ខែវិច្ឆិកា ឆ្នាំ 2004, 57។

6. សូមមើល គ. និង ស. 128:19 ។

7. កូរិនថូសទី 1 2:11 & 14។

8. សូមមើល យ៉ូហាន 7:16-17, យ៉ាកុប 4:8 ។

9. យ៉ូប 32:8។

10. សូមមើល គ. និង ស. 130:20--21។

11. ការសង្កេតផ្ទាល់ខ្លួន--- ដូចជាត្រីវិស័យ គោលការណ៍ទាំងឡាយផ្ដល់ជាចំនុចបញ្ជាក់ នៅក្នុងដំណើរជីវិត។

12. សូមមើល *លីអាហូណា* ខែ តុលា ឆ្នាំ 2004, 49។

13. លោកុប្បត្តិ 2:24។

14. សូមមើល គ. និង ស. 49:15-17។

15. សូមមើល គ. និង ស. 68:25-28។

16. នីហ្វៃទី 2 5:27។

17. នីហ្វៃទី 2 22:3។

18. យ៉ូហាន 10:10។

19. សូមមើល គ. និង ស. 82:10។

20. សូមមើល គ. និង ស. 130:2។

21. ដកស្រង់ចេញពី *Expressions of Comfort* (Uhrichsville, Ohio: Barbour Publishing, 2007) 187--88 ។ បានប្រើប្រាស់ដោយមានការអនុញ្ញាត។